**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

Downloaded from http://www.khmerlaws.com

- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាពនៅតាមក្រសួង ស្ថាប័ននានា ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពការងារ និងគណនេយ្យភាព ក្នុងការអនុវត្តឱ្យបានសម្រេចជោគជ័យនូវការងារអាទិភាពនៃក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

កន្សោមអាទិភាព គឺជាក្រុមមន្ត្រីរាជការដែលត្រូវបានជ្រើសរើស ដើម្បីអនុវត្តឱ្យបានជោគជ័យនូវប្រតិបត្តិការអាទិភាព និងមានការទទួលខុសត្រូវចំពោះមុខថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ។

## ជំពូកទី២

## ការបង្កើតកន្សោមអាទិភាព

**មាត្រា ៣.-**

ក្រសួង ស្ថាប័ន ត្រូវកំណត់អត្តសញ្ញាណបេសកកម្មអាទិភាព ដោយផ្អែកលើឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពអភិបាលកិច្ច ។

កន្សោមអាទិភាព ត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែម និងពង្រឹងឧបករណ៍ប្រសិទ្ធភាពការងារផ្សេងៗ ដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេស និងការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

**មាត្រា ៤.-**

ក្រសួង ស្ថាប័ន ត្រូវរៀបចំដាក់សំណើ ស្តីពីការបង្កើតកន្សោមអាទិភាព មកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីសុំការអនុមតិជាគោលការណ៍ ។

សំណើនៃការបង្កើតកន្សោមអាទិភាព ត្រូវមានការបញ្ជាក់ពី :

- សេចក្តីប្រកាសបេសកកម្ម
- លទ្ធផលរំពឹងទុក
- ចំនួនមុខតំណែង
- ចរិកាសម្រាប់ឧបត្ថម្ភសមាជិក
- កិច្ចសន្យាគ្រប់គ្រង និងកិច្ចសន្យាការងារ ។

Downloaded from http://www.khmerlaws.com

មាត្រា ៥.-

បន្ទាប់ពីគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ពិនិត្យ និងអនុម័តលើសំណើស្ដីពីការបង្កើតកន្សោមអាទិភាពរួចហើយ ក្រសួង ស្ថាប័នត្រូវរៀបចំឯកសារក្របខ័ណ្ឌដូចមានបញ្ជាក់នៅក្នុងឯកសារណែនាំស្ដីពីការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។ ក្រសួង ស្ថាប័ន ត្រូវរៀបចំ ជ្រើសរើសមន្ត្រីរាជការទៅតាមនីតិវិធី និងតម្លាភាព ហើយត្រូវដាក់ស្នើបញ្ជីឈ្មោះមន្ត្រីដែលនឹងត្រូវតែងតាំងមកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីពិនិត្យ និងអនុម័តជាចុងក្រោយ ។

មាត្រា ៦.-

ក្រោយពីទទួលបានការអនុម័តចុងក្រោយពីគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និង គណនេយ្យភាពរួចហើយ ក្រសួង ស្ថាប័ន ត្រូវដាក់ឱ្យអនុវត្តកន្សោមអាទិភាព ដូចខាងក្រោម ៖

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានមួយផ្នែកដោយថវិការួមរបស់បណ្ដាដៃគូអភិវឌ្ឍន៍ រដ្ឋមន្ត្រី ឬ តំណាងក្រសួង ស្ថាប័ន ត្រូវចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្ដាដៃគូអភិវឌ្ឍន៍ និងត្រូវចេញប្រកាសតែងតាំងមន្ត្រី ព្រមទាំងអនុម័តលើឯកសារណែនាំសម្រាប់អនុវត្ត និងដាក់ឱ្យដំណើរការកន្សោមអាទិភាព។

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានទាំងស្រុងដោយថវិកាជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវចេញប្រកាសតែងតាំងមន្ត្រី ព្រមទាំងអនុម័តលើឯកសារណែនាំសម្រាប់អនុវត្ត និងដាក់ឱ្យដំណើរការកន្សោមអាទិភាព។

ឯកសារណែនាំត្រូវចែងលំអិតអំពីនីតិវិធី និងដំណើរការនៃការអនុវត្តកន្សោមអាទិភាពនីមួយៗ ស្របទៅតាមឯកសារណែនាំស្ដីពីការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។

មាត្រា ៧.-

ការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី៣

## ទំហំ និងការជ្រើសរើសសមាជិកកន្សោមអាទិភាព

មាត្រា ៨.-

កន្សោមអាទិភាពនឹងត្រូវរៀបចំឡើងសម្រាប់មុខតំណែងដែលចាំបាច់ ដើម្បីសម្រេចគោលដៅ និងលទ្ធផលដែលបានគ្រោងទុក។

នៅពេលដែលមុខតំណែងកន្សោមអាទិភាពត្រូវបានបង្កើតឡើងសម្រាប់បំពេញបន្ថែមទៅលើមុខតំណែង

Downloaded from http://www.khmerlaws.com

នៃការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ការបង្កើតមុខតំណែងនេះត្រូវផ្អែកលើការងារដែលទ្រទ្រង់ដល់ការបង្កើតមុខតំណែងសម្រាប់អនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

សមាជិកកន្សោមអាទិភាពត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នសាមី និងស្ថិតនៅក្នុងប្រភេទក្របខ័ណ្ឌ **ក ខ និង គ** ។

ការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវផ្អែកលើលក្ខណៈសម្បត្តិស័ក្តិសម និងបទពិសោធន៍ការងារដែលបញ្ជាក់ច្បាស់លាស់នៅក្នុងតម្រូវការមុខតំណែង ។

**មាត្រា ៩.-**

ដំណើរការជ្រើសរើសសមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងដោយផ្អែកលើការវាយតម្លៃយ៉ាងសម្រិតសម្រាំង និងមានតម្លាភាព។ ការជ្រើសរើសត្រូវផ្អែកទៅលើតម្រូវការមុខតំណែង និងត្រូវធ្វើការប្រកាសផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងក្រសួង ស្ថាប័នសាមី ។

**មាត្រា ១០.-**

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាសមាជិកកន្សោមអាទិភាព ត្រូវចុះកិច្ចសន្យាការងារ។ សមាជិកកន្សោមអាទិភាពដែលមិនអនុវត្តតាមកិច្ចសន្យាការងារ នឹងត្រូវបញ្ឈប់ពីសមាជិកភាពនៃកន្សោមអាទិភាព ។

**មាត្រា ១១.-**

ទំហំ និងសមាសភាពនៃកន្សោមអាទិភាពនីមួយៗ អាស្រ័យទៅលើតម្រូវការមុខងារប្រតិបត្តិការអាទិភាពដែលបានកំណត់ក្នុងបេសកកម្ម និងលទ្ធភាពនៃការធ្វើហិរញ្ញប្បទានពីថវិកាជាតិ និង/ឬ ពីបណ្តាដៃគូអភិវឌ្ឍន៍ សម្រាប់ចំណាយលើប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រីដែលត្រូវបានតែងតាំងជាសមាជិកកន្សោមអាទិភាព ។

មុខតំណែងកន្សោមអាទិភាពនីមួយៗ ត្រូវមានការពណ៌នាបញ្ជាក់អំពីមុខតំណែង តួនាទី ភារកិច្ច និងតម្រូវការសមត្ថភាពវិជ្ជាជីវៈ ។

## ជំពូកទី៤
## អត្ថប្រយោជន៍សម្រាប់សមាជិកកន្សោមអាទិភាព

**មាត្រា ១២.-**

សមាជិកកន្សោមអាទិភាពនឹងទទួលបាននូវអត្ថប្រយោជន៍ពីរយ៉ាង គឺ :

- ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើលទ្ធផលការងារប្រចាំខែ ដូចមានចែងក្នុងមាត្រា១៣ និងមាត្រា១៤
- មានអាទិភាពក្នុងឱកាសបណ្តុះបណ្តាលសម្រាប់ពង្រឹងការងារកន្សោមអាទិភាព និងការអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួន ។

Downloaded from http://www.khmerlaws.com

សមាជិកកន្សោមអាទិភាព បន្តទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗដូចមន្ត្រីរាជការដទៃទៀតដែលបានកំណត់នៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ។

មន្ត្រីដែលបានតែងតាំងជាសមាជិកកន្សោមអាទិភាព នឹងមិនត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តពីគម្រោងផ្សេងៗទៀត ឡើយ ។

**មាត្រា ១៣.-**

សមាជិកកន្សោមអាទិភាពដែលបានបំពេញការងារគ្រប់លក្ខខ័ណ្ឌនៃកិច្ចសន្យាការងារ នឹងទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំខែ ដូចខាងក្រោម :

- ប្រភេទ ក ៥២០ ០០០ (ប្រាំរយម្ភៃពាន់) រៀល ក្នុងមួយខែ
- ប្រភេទ ខ ៤៥០ ០០០ (បួនរយហាសិបពាន់) រៀល ក្នុងមួយខែ
- ប្រភេទ គ ៣៥០ ០០០ (បីរយហាសិបពាន់) រៀល ក្នុងមួយខែ

**មាត្រា ១៤.-**

ប្រធានគម្រោងកន្សោមអាទិភាពនីមួយៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៦០០ ០០០ (ប្រាំមួយរយពាន់) រៀល ក្នុងមួយខែ ហើយមិនអាចទទួលបានប្រាក់ឧបត្ថម្ភក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះបានឡើយ ។

មន្ត្រីនៅតាមក្រសួង ស្ថាប័ន ដែលកំពុងចាត់ចែងការបង្កើត ការគ្រប់គ្រង និងតាមដានត្រួតពិនិត្យគ្រប់កម្មវិធីកន្សោមអាទិភាពនៅក្នុងយុត្តាធិការរបស់ខ្លួន នឹងត្រូវបានទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តស្របតាមលក្ខខ័ណ្ឌនៃអនុក្រឹត្យនេះ ឬលក្ខខ័ណ្ឌនៃអនុក្រឹត្យ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

**មាត្រា ១៥.-**

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានទាំងស្រុងដោយថវិកាជាតិ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់សមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងតាមតារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធព័ត៌មានវិទ្យារបស់រាជរដ្ឋាភិបាល ។

នៅពេលដែលកន្សោមអាទិភាព ត្រូវបានធ្វើហិរញ្ញប្បទានមួយផ្នែកដោយថវិកាជាតិ និងមួយផ្នែកដោយថវិការួមគ្នារបស់បណ្តាដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវគោរពទៅតាមចំណែកដូចបានកំណត់ទៅតាមករណីដែលមានចែងនៅក្នុង ឯកសារក្របខ័ណ្ឌស្តីពីការបង្កើតកន្សោមអាទិភាព។ ក្នុងករណីនេះ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់សមាជិកកន្សោមអាទិភាព ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធធនាគារ ក្រោមរូបភាពបង្វែរសាច់ប្រាក់ពីគណនីគម្រោង ដែលបានព្រមព្រៀងគ្នាដោយរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ទៅក្នុងគណនីផ្ទាល់ខ្លួនរបស់សមាជិកកន្សោមអាទិភាពម្នាក់ៗ ។

Downloaded from http://www.khmerlaws.com

មាត្រា ១៦.-

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តសម្រាប់ការអនុវត្តការងារ ដូចបានកំណត់ក្នុងមាត្រា ១៣ និងមាត្រា ១៤ នៃអនុក្រឹត្យនេះ អាចធ្វើការផ្លាស់ប្តូរបាន អាស្រ័យតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ ។

មាត្រា ១៧.-

មន្ត្រីរាជការដែលបានទទួលប្រាក់បំណាច់មុខងារតាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល និងមាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ និងបទដ្ឋានពាក់ព័ន្ធផ្សេងទៀត មានកាតព្វកិច្ចជំរុញដំណើរការកន្សោមអាទិភាពឱ្យប្រព្រឹត្តទៅបានល្អប្រសើរតាមការចាត់តាំងរបស់ប្រធានស្ថាប័ន ។ មន្ត្រីទាំងនេះមិនត្រូវបានទទួលប្រាក់ឧបត្ថម្ភពីការអនុវត្តកម្មវិធីកន្សោមអាទិភាពឡើយ លើកលែងតែប្រធានគម្រោងកន្សោមអាទិភាពដែលបានកំណត់ក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៥
## ការគ្រប់គ្រងកន្សោមអាទិភាព

មាត្រា ១៨.-

កន្សោមអាទិភាពដែលបង្កើតឡើងដោយក្រសួង ស្ថាប័នសាមី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយផ្ទាល់របស់ក្រសួង ស្ថាប័នសាមី ។

ក្រសួង ស្ថាប័ន ដែលបង្កើតកន្សោមអាទិភាព ត្រូវទទួលខុសត្រូវចំពោះការដាក់ឱ្យដំណើរការកន្សោមអាទិភាព និងធានាចំពោះការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ការដាក់ឱ្យដំណើរគម្រោងដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ។

មាត្រា ១៩.-

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព អាចផ្តល់ជំនួយផ្នែកបច្ចេកទេសតាមការចាំបាច់ដល់ក្រសួង ស្ថាប័ន ហើយមានសិទ្ធិក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើដំណើរការអនុវត្តកន្សោមអាទិភាព ។

មាត្រា ២០.-

ក្រសួង ស្ថាប័ន ត្រូវតែងតាំងថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូបជានាយកកម្មវិធីកន្សោមអាទិភាព ដើម្បីដឹកនាំសម្របសម្រួល និងតាមដានត្រួតពិនិត្យ ដល់ការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព តាមយុត្តាធិការរៀងៗខ្លួន ។

Downloaded from http://www.khmerlaws.com

មាត្រា ២១.-

សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់នាយកកម្មវិធីកន្សោមអាទិភាព ត្រូវកំណត់នៅក្នុងឯកសារក្របខ័ណ្ឌនៃការបង្កើតកន្សោមអាទិភាពនីមួយៗ ស្របតាមឯកសារណែនាំ សម្រាប់ការបង្កើត និងការគ្រប់គ្រងកន្សោមអាទិភាព ។

មាត្រា ២២.-

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវទទួលខុសត្រូវចំពោះការសម្របសម្រួលដល់ការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យកម្មវិធីកន្សោមអាទិភាពនៅតាមក្រសួង ស្ថាប័ននីមួយៗ ។

ទោះបីជាកន្សោមអាទិភាពនីមួយៗមិនមានកំណត់រយៈពេលជាក់លាក់សម្រាប់ការដាក់ឱ្យដំណើរការក្តី ក៏ប៉ុន្តែត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃយ៉ាងហោចណាស់មួយឆ្នាំម្តងៗ ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពការងារ ការពិចារណាគួរបន្តអនុវត្ត និងដាក់ចេញជាវិធានការសម្រាប់កែលំអប្រសិទ្ធភាពការងារ ។

## ជំពូកទី៦

## ប្រភពថវិកាសម្រាប់ដំណើរការកន្សោមអាទិភាព

មាត្រា ២៣.-

ថវិកាសម្រាប់ដំណើរការកន្សោមអាទិភាព មានប្រភពមកពី :

- ថវិកាជាតិ
- ថវិកាហិរញ្ញប្បទានពីបណ្តាដៃគូអភិវឌ្ឍន៍ ។

ថវិកាបដិភាគដែលបានមកពីថវិកាជាតិ និងពីបណ្តាដៃគូអភិវឌ្ឍន៍សម្រាប់ធ្វើហិរញ្ញប្បទានដល់កម្មវិធីកន្សោមអាទិភាពនីមួយៗ នឹងត្រូវកំណត់នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល និងបណ្តាដៃគូអភិវឌ្ឍន៍ ដោយមានការព្រមព្រៀងគ្នាទាំងសងខាង ។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

មាត្រា ២៤.-

កន្សោមអាទិភាពដែលកំពុងដាក់ឱ្យដំណើរការនៅតាមក្រសួង ស្ថាប័ន ត្រូវបន្តអនុវត្តតាមខ្លឹមសារដូចមានចែងនៅក្នុងសេចក្តីសម្រេចក្នុងការបង្កើតកន្សោមអាទិភាពនោះ ហើយការបើកផ្តល់ប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាពទាំងនោះត្រូវអនុវត្តតាមអនុក្រឹត្យនេះក្រោយពេលចូលជាធរមាន ។

ចំពោះកន្សោមអាទិភាពដែលកំពុងដំណើរការ ហើយដែលគ្រោងនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃឡើងវិញ អាចនឹងត្រូវបានពន្យារពេលប្រសិនបើកន្សោមអាទិភាពនោះស្របទៅនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ។ ការពន្យារពេលត្រូវសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

Downloaded from http://www.khmerlaws.com

# ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព និងអនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលកម្រិតប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាព ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត
- ដូចមាត្រា ២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com